# របាយការណ៍

## ស្ថានភាពសិទ្ធិដីធ្លី៖ ឆ្លុះបញ្ចាំងនិយ័តកម្មច្បាប់ និងប្រសិទ្ធិភាពអនុវត្ត
## ជុំវិញស្ថានភាពវិវាទដីធ្លីរវាងបុគ្គលមានទ្រព្យ មានអំណាច
## និងប្រជាសហគមន៍នៅកម្ពុជា

**ភ្នំពេញ  ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០២៦**

Address: #3, St 158 Ouknha Trorung Kang, Boeng Raing, Saun Penh, Phnom Penh
Tel: (+855-23) 218 553/210 518/990 544
P.O Box: 1024 – P.O Box 20 at CCC
E-mail: info@adhoccambodia.org
Website: www.adhoccambodia.org
Facebook: www.facebook.com/adhoccam
Twitter: www.twitter.com/adhoccam

# មាតិកា

I. សេចក្តីផ្តើម ....................................................................................................................... 3
II. ស្ថានភាពអនុវត្តច្បាប់ក្នុងការគ្រប់គ្រងជីឃ្លី........................................................................................... 5
III. តួនាទី និងឥទ្ធិពលបុគ្គលមានអំណាច និងអ្នកមានទ្រព្យ(ក្រុមហ៊ុន)........................................................... 6
IV. ផលវិបាកប៉ះពាល់ដល់សង្គម និងប្រជាពលរដ្ឋ........................................................................................ 8
V. ការវាយតម្លៃប្រសិទ្ធិភាពនៃនិយ័តកម្មច្បាប់.......................................................................................... 9
VI. សេចក្តីសន្និដ្ឋាន .................................................................................................................. 10
VII. ដំណោះស្រាយ និងអនុសាសន៍.......................................................................................................... 10

## I. សេចក្ដីផ្ដើម

ដីធ្លីគឺជាមូលដ្ឋានធនធានធម្មជាតិសំខាន់បំផុតមួយសម្រាប់ ការអភិវឌ្ឍសេដ្ឋកិច្ច-ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ សន្តិសុខសង្គម និងអត្តសញ្ញាណវប្បធម៌របស់ប្រទេសជាតិនិមួយៗនៅលើសកលលោក។ នៅកម្ពុជាដីធ្លីមិនត្រឹមតែជាមូលដ្ឋានសម្រាប់ ផលិតផលកសិ-ឧស្សាហកម្មប៉ុណ្ណោះទេ ថែមទាំងបញ្ជាក់អំពីអត្តសញ្ញាណ សេរីភាពរស់នៅ និងសុវត្ថិភាពសង្គមរបស់ប្រជាពលរដ្ឋ។ របាយការណ៍នេះ **មានគោលបំណងវិភាគពីស្ថានភាពសិទ្ធិដីធ្លីនៅកម្ពុជា ដោយផ្ដោតលើការផ្ទុះបញ្ចាំងរវាងនិយ័តកម្មច្បាប់ និងប្រសិទ្ធិភាពអនុវត្ត ជាពិសេសចំពោះអ្នកមានឥទ្ធិពលក្នុងសង្គម។**

ទោះបីជាកម្ពុជា មានក្របខណ្ឌច្បាប់ស្ដីពីដីធ្លីយ៉ាងច្បាស់លាស់ក៏ដោយ ការអនុវត្តជាក់ស្ដែងនៅតែមានបញ្ហាប្រឈមយ៉ាងខ្លាំង ជាពិសេសនៅពេលមានការពាក់ព័ន្ធនឹងបុគ្គលមានទ្រព្យ និងបុគ្គលមានអំណាច ដែលបានបង្កើតជាបញ្ហាចម្រុះរួមមានផ្នែក **ច្បាប់ សង្គម អភិបាលកិច្ច និងសិទ្ធិមនុស្ស**។ បញ្ហានេះ បង្កឱ្យមានជម្លោះដីធ្លីរវាងអាជ្ញាធរ បុគ្គលមានអំណាច-បុគ្គលមានទ្រព្យ(ក្រុមហ៊ុន) ជាមួយប្រជាពលរដ្ឋក្នុងសហគមន៍ ដែលភាគច្រើនពឹងផ្អែកលើដីសម្រាប់ធ្វើកសិកម្មដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃ លើសពីនេះទៀតជម្លោះដីធ្លីរាំរ៉ៃនេះ បានប្រែក្លាយទៅជាបទល្មើស(ករណី)ព្រហ្មទណ្ឌជាច្រើនកើតចេញឡើង ក្រោមការប្ដឹងចោទប្រកាន់ពី ភាគីអ្នកមានអំណាច-ក្រុមហ៊ុនអ្នកមានទ្រព្យ មកលើប្រជាពលរដ្ឋក្នុងសហគមន៍។ បញ្ហាទាំងនេះ បង្កើតជា ការខ្វះជំនឿទុកចិត្តរវាងប្រជាពលរដ្ឋ និងអាជ្ញាធរ។

តាមទិន្នន័យរកឃើញដោយសមាគមអាដហុកក្នុងឆ្នាំ២០២៥ បញ្ហាវិវាទដីធ្លីនៅកម្ពុជា នៅតែបន្តមានលក្ខណៈធ្ងន់ធ្ងរ និងស្មុគស្មាញ ដោយមានករណីថ្មីចំនួន៤៥ ករណី បន្ថែមលើករណីចាស់ៗជាច្រើនដែលមិនទាន់មានដំណោះស្រាយសមរម្យនៅឡើយ។ ករណីថ្មីចំនួន៤៥នេះ បានប៉ះពាល់ដល់ប្រជាពលរដ្ឋចំនួន៥,៥២០ គ្រួសារ(ស្មើ ១៤,៧៩៨ នាក់) រួមមានស្ត្រី ៦,៧០៣ នាក់ និងជនជាតិដើមភាគតិច ៧,៣៥១ នាក់ ដែលពាក់ព័ន្ធនឹងផ្ទៃដីសរុបប្រមាណ ១១៥,៤១៣ ហិកតា។

ក្នុងចំណោមករណីទាំងនេះ មាន ៤២% ជាករណីរំលោភដីធ្លីដោយបុគ្គលមានអំណាច និង ២០% ជាករណីរំលោភដីធ្លីដោយបុគ្គលអ្នកមានទ្រព្យ ឬក្រុមហ៊ុន ដែលបង្ហាញពីឥទ្ធិពលខ្លាំងរបស់ក្រុមអ្នកមានអំណាចលើការគ្រប់គ្រងធនធានដីធ្លី។ ជាពិសេស មាន ២១ ករណីបានបង្ហាញពីការគំរាមកំហែង ដែលបង្កឲ្យតំណាងសហគមន៍មិនអាចចូលដីជម្លោះ និងមានមនុស្សមួយចំនួនប្រឈមមុខនឹងបណ្ដឹងព្រហ្មទណ្ឌ និងការឃុំខ្លួន។

ការអនុវត្តច្បាប់ដីធ្លីនៅកម្ពុជា បង្ហាញពីគម្លាតរវាងទ្រឹស្ដី និងការអនុវត្តជាក់ស្ដែង ដោយមានបញ្ហាដូចជា ការអនុវត្តមិនស្មើភាព ការខ្វះតម្លាភាព អំពើពុករលួយ និងឥទ្ធិពលរបស់អ្នកមានអំណាច និងអ្នកមានទ្រព្យ។ សកម្មភាពរួមមាន ការដកហូតដីដោយគ្មានសំណងសមរម្យ ការប្រើកម្លាំង និងអាវុធគំរាមកំហែង ការបំផ្លាញទ្រព្យសម្បត្តិ-ផលដំណាំកសិកម្ម និងការប្រើប្រព័ន្ធតុលាការដើម្បីដាក់សម្ពាធលើប្រជាសហគមន៍។

បញ្ហានេះបានបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់សិទ្ធិមនុស្ស និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋសហគមន៍ រួមមានការបាត់បង់ដីធ្លី និងប្រភពចំណូល ភាពក្រីក្រ បញ្ហាសុខភាពផ្លូវចិត្ត និងអស្ថិរភាពសង្គម។ ជាពិសេស ជនជាតិដើមភាគតិចប្រឈមនឹងការបាត់បង់ដីវប្បធម៌ អត្តសញ្ញាណ និងធនធានធម្មជាតិ ដោយមិនគោរពគោលការណ៍ "ការយល់ព្រមជាមុនដោយសេរី និងមានព័ត៌មានពេញលេញ (FPIC)"។

សរុបមក វិវាទដីធ្លីនៅកម្ពុជា មិនត្រឹមតែជាបញ្ហាបច្ចេកទេសធម្មតាទេ ប៉ុន្តែជាបញ្ហាដែលពាក់ព័ន្ធយ៉ាងស៊ីជម្រៅទៅនឹង **អំណាច សេដ្ឋកិច្ច សិទ្ធិមនុស្ស និងអភិបាលកិច្ច**។ ដើម្បីដោះស្រាយបញ្ហានេះ ត្រូវការកែលម្អការអនុវត្តច្បាប់ឲ្យមានប្រសិទ្ធិភាព និងតម្លាភាព ពង្រឹងឯករាជ្យភាពតុលាការ ការពារសិទ្ធិសហគមន៍ និងទប់ស្កាត់អំពើពុករលួយ ដើម្បីធានាការប្រើប្រាស់ដីធ្លីដោយយុត្តិធម៌ និងសមភាពសង្គម។




យោងតាមទិន្នន័យឆ្នាំ២០២៥ សមាគមអាដហុកបានរកឃើញ ករណីវិវាទដីធ្លីថ្មីកើតឡើង ចំនួន៤៥ករណីបន្ថែមលើករណីចាស់ៗរាប់រយ ដែលមិនទាន់មានដំណោះស្រាយសមរម្យ និងច្បាស់លាស់នៅឡើយ។ ក្នុងចំណោមករណីថ្មី ៤៥ នោះ មានជនរងគ្រោះផ្ទាល់ចំនួន ៥,៥២០គ្រួសារ មានចំនួនមនុស្ស ១៤,៧៩៨នាក់(ស្ត្រី៦,៧០៣នាក់) និងជនជាតិដើមភាគតិចចំនួន ៧,៣៥១នាក់ - ប៉ះពាល់ដីចំនួន ១១៥,៤១៣ ហិចតា។ហើយក្នុងនោះ មាន៤២% (១៩ករណី) ជាករណីរំលោភដីធ្លីដោយបុគ្គលមានអំណាច[1] និងករណីរំលោភដីធ្លីដោយបុគ្គលអ្នកមានទ្រព្យ ២០% (៩ករណី)។

ក្នុងចំណោម វិវាទដីធ្លី៤៥ករណី មាន២១ករណីទទួលរងការគម្រាមកំហែង ពីអ្នកមានអំណាច និងអ្នកមានទ្រព្យ ដែលបណ្តាលឲ្យតំណាងសហគមន៍ក្នុងដីជម្លោះ (១៧៤នាក់) មិនហ៊ានចូលកន្លែងដីជម្លោះ ហើយក្នុងនោះ មានតំណាងសហគមន៍ចំនួន ២៥នាក់កំពុងជាប់បណ្តឹងព្រហ្មទណ្ឌនៅតុលាការ០២នាក់ត្រូវបានឃុំខ្លួនបណ្តោះអាសន្ន និង០២នាក់ត្រូវបានឃាត់ខ្លួនដើម្បីធ្វើកិច្ចសន្យាឈប់តវ៉ា។

**ការរំលោភដោយបុគ្គលមានអំណាច៖** នៅក្នុងឆ្នាំ២០២៥ មាន១៩ករណីរំលោភដីធ្លី ដោយបុគ្គលមានអំណាច លើដីប្រមាណ ៨៩៣ហិកតា ដែលនាំឲ្យប៉ះពាល់ផ្ទាល់ដល់ប្រជាសហគំន៍ ១,៥៧៣គ្រួសារ (ចំនួនមនុស្ស៤,៨៦១នាក់ - ស្ត្រី ២,៨៩១នាក់) ហើយក្នុងនោះ មានជនជាតិដើមភាគតិចចំនួន៤៦%(ចំនួនមនុស្ស២,២៤៥នាក់)។

[1] *បុគ្គលមានអំណាចរួមមាន៖ មន្ត្រីរាជការស៊ីវិល ជាកងកំលាំងប្រដាប់អាវុធ ជាបុគ្គលស្ថិតនៅក្នុងស្ថាប័នរាជការស៊ីវិល និងស្ថាប័នប្រដាប់អាវុធ និង ជាពលរដ្ឋមានអ្នកមានអំណាចនៅពីក្រោយ មានដូចជា ឧត្តមសេនីយ៍ ទីប្រឹក្សាអ្នកមានអំណាច កងរាជអាវុធហត្ថខេត្ត នគរបាលព្រំដែន ក្រុមប្រឹក្សាស្រុក រដ្ឋបាលព្រៃឈើ ក្រុមប្រឹក្សាខេត្ត និងមន្ត្រីយោធាជាដើម។*

**ការរំលោភដោយបុគ្គលមានទ្រព្យ (ក្រុមហ៊ុន)៖** នៅក្នុងឆ្នាំ២០២៥ មាន០៩ករណីរំលោភដីធ្លី ដោយបុគ្គលមានទ្រព្យ (ក្រុមហ៊ុន) លើដីប្រមាណ ៣៩,៨១៥ហិកតា ដែលនាំឲ្យប៉ះពាល់ផ្ទាល់ដល់សហគមន៍ ២,១៩៨គ្រួសារ(ចំនួនមនុស្ស ៦,៩៥០នាក់-ស្ត្រី៣,៣៦៦នាក់) ហើយក្នុងនោះមាន ៦១%(ចំនួនមនុស្ស៤,២១៨នាក់) គឺជាជនជាតិដើមភាគតិច។

## II. ស្ថានភាពអនុវត្តច្បាប់ក្នុងការគ្រប់គ្រងដីធ្លី

ការអនុវត្តច្បាប់ដីធ្លីនៅកម្ពុជា បង្ហាញពីគម្លាតយ៉ាងច្បាស់រវាងទ្រឹស្តី និងការអនុវត្តជាក់ស្តែង។ បញ្ហាចម្បងរួមមាន ការអនុវត្តន៍ច្បាប់មិនស្មើភាព ឬមិនមានឯករាជ្យភាពពេញលេញក្នុងការស្វែងរកយុត្តិធម៌ ការខ្វះតម្លាភាព អំពើពុករលួយដោយមានការសហការរវាងអាជ្ញាធរមានអំណាច និងមូលធនអ្នកមានទ្រព្យ (ក្រុមហ៊ុន)។ បញ្ហាទាំងនេះធ្វើឱ្យមានការលំបាកក្នុងការការពារសិទ្ធិដីធ្លីរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ និងការអនុវត្តន៍ច្បាប់ភូមិបាល អនុក្រិត្យ និងវិធានច្បាប់ពាក់ព័ន្ធមិនមានប្រសិទ្ធិភាព។ បញ្ហានេះបង្ហាញថា វិវាទដីធ្លីមិនត្រឹមតែជាបញ្ហាបច្ចេកទេសធម្មតាទេ ប៉ុន្តែជាបញ្ហាដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស អំណាច សេដ្ឋកិច្ច និងអភិបាលកិច្ច។

តាមការសង្កេត និងប្រមូលព័ត៌មានពីសហគមន៍ បានបង្ហាញឲ្យឃើញថា មានករណីរំលោភបំពានដីធ្លីជាច្រើនដែលពាក់ព័ន្ធនឹងបុគ្គលមានអំណាច និងអ្នកមានទ្រព្យ(ក្រុមហ៊ុន) ដូចខាងក្រោម៖

**ការអនុវត្តន៍លើសគោលបំណងច្បាប់កំណត់៖** យោងតាមការអង្កេតប្រមូលព័ត៌មាន ៤៥ករណីវិវាទដីធ្លីឆ្នាំ២០២៥ បានបង្ហាញឲ្យឃើញថា អាជ្ញាធរមានសមត្ថកិច្ច បុគ្គលមានអំណាច-មានទ្រព្យ(ក្រុមហ៊ុន) បានប្រើអំណាចដកហូតដីដោយមិនមានសំណងសមរម្យតាមតម្លៃទីផ្សារ ការប្រើកម្លាំងប្រដាប់អាវុធដើម្បីគំរាមប្រជាសហគមន៍ ព្រមទាំងការប្រើគ្រឿងចក្រឈូសឆាយដី បំផ្លាញទ្រព្យសម្បត្តិ ផលដំណាំប្រជាសហគមន៍។

**ការដកហូតដីដោយគ្មានផ្តល់សំណងសមរម្យតាមទីផ្សារ និងការរារាំងការតវ៉ា៖** គឺផ្ទុយស្មារតីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣៥ធានាសិទ្ធិប្រជាពលរដ្ឋក្នុងការចូលរួមនិងធ្វើការតវ៉ាដោយសន្តិវិធី និងមាត្រា៤៤ ធានាសិទ្ធិកម្មសិទ្ធិឯកជន ការមិនអាចដកហូតបាន លុះត្រាតែមានប្រយោជន៍សាធារណៈ និងផ្តល់សំណងសមរម្យជាមុន។

**ការដកហូតយកដីដែលប្រជាពលរដ្ឋកាន់កាប់ជាង១០ឆ្នាំ៖** គឺជាការរំលោភលើសិទ្ធិកាន់កាប់ ដោយសុចរិត ផ្ទុយស្មារតីច្បាប់ភូមិបាលឆ្នាំ២០០១ ត្រង់មាត្រា៥ទទួលស្គាល់កម្មសិទ្ធិឯកជន និងមាត្រា៣០ សិទ្ធិកាន់កាប់ដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី៥ឆ្នាំយ៉ាងតិច។

**ការឈូសឆាយដីព្រៃសហគមន៍ជនជាតិដើមភាគតិច៖** គឺជាការរំលោភសិទ្ធិជនជាតិដើមភាគតិច ដូចមានចែងក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ ផ្នែទី២ ត្រង់មាត្រា២៣ ដល់ មាត្រា២៨ ធានាអចលនវត្ថុរបស់សហគមន៍ជនជាតិដើមភាគតិច។

**ការបាត់បង់ដីធ្លី ដែលបានប៉ះពាល់ដល់សិទ្ធិជីវភាពរស់នៅ និងចំណីអាហារ៖** គឺផ្ទុយស្មារតី កតិកាអន្តរជាតិស្តីអំពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ត្រង់មាត្រា១១ ធានាសិទ្ធិលំនៅឋានសមរម្យ និងជីវភាពសមរម្យ។

**ការឈូសឆាយដី ប៉ះពាល់ដល់អត្តសញ្ញាណ និងវប្បធម៌ របស់សហគមន៍ជនជាតិដើមភាគតិច៖** គឺជាការរំលោភសិទ្ធិជនជាតិដើមភាគតិច ផ្ទុយស្មារតីសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនជាតិដើមភាគតិច ត្រង់មាត្រា១០ មិនអនុញ្ញាតឲ្យបណ្តេញចេញពីដីដោយគ្មានការយល់ព្រម មាត្រា២៦ សិទ្ធិនៅលើដី និងធនធានសហគមន៍ជនជាតិភាគ

តិច និងមាត្រា៣២ មានអត្ថន័យសំដៅដល់ចំណុច ការយល់ព្រមដោយសេរី ជាមុន និងដោយមានព័ត៌មានពេញលេញ (FPIC)។

## III. តួនាទី និងឥទ្ធិពលបុគ្គលមានអំណាច និងអ្នកមានទ្រព្យ(ក្រុមហ៊ុន)

អ្នកមានទ្រព្យ និងអ្នកមានអំណាច មានឥទ្ធិពលយ៉ាងខ្លាំងលើការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីនៅកម្ពុជា។ ក្រុមអ្នកមានទ្រព្យអាចទទួលបានដីធ្លីធំៗតាមរយៈសម្បទានដីសេដ្ឋកិច្ច[2]ខណៈដែលអ្នកមានអំណាចអាចមានឥទ្ធិពលលើការសម្រេចចិត្ត ក្នុងការផ្តល់ដី និងប្រើប្រាស់អំណាចក្នុងការធ្វើបណ្តឹង ឬការស្វែងរកដំណោះស្រាយ។ ការសហការគ្នា រវាងការធ្វើអាជីវកម្មនិងនយោបាយ បង្កើតជាបណ្តាញអំណាច ដែលអាចប៉ះពាល់ដល់ការអនុវត្តច្បាប់។

តាមការសង្កេត និងប្រមូលព័ត៌មានពីសហគមន៍ បានបង្ហាញឲ្យឃើញថា មានករណីរំលោភបំពានដីធ្លីជាច្រើនដែលពាក់ព័ន្ធនឹងទំនាក់ទំនងសហការរវាងបុគ្គល(អាជ្ញាធរ)មានអំណាច និងបុគ្គលមានទ្រព្យ(ក្រុមហ៊ុន) ក្នុងការអភិវឌ្ឍន៍ និងគ្រប់គ្រងដីធ្លីដូចខាង៖

**ការដកហូតដីពីប្រជាពលរដ្ឋដោយមន្ត្រីបរិស្ថាន**[3]៖ មន្ត្រីបរិស្ថានខេត្តបានដកហូត ដីចំការរបស់ប្រជាពលរដ្ឋ ដែលត្រូវបានរដ្ឋាភិបាលកាត់ឆ្វៀលជូនសម្រាប់ប្រើប្រាស់អាស្រ័យផល តាមអនុក្រឹត្យលេខ ២៤៥ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០២២។ បន្ទាប់មក អាជ្ញាធរបានវាស់វែង និងយកដីនោះទៅលក់ឲ្យឈ្មួញ ហើយមានការគំរាមកំហែងចាប់ខ្លួនប្រជាពលរដ្ឋដែលតវ៉ា។ ករណីនេះបាននាំឲ្យមានការចាប់ខ្លួនតំណាងប្រជាពលរដ្ឋម្នាក់ និងបង្ខំឲ្យចុះកិច្ចសន្យាឈប់តវ៉ា ជាថ្នូរនឹងការដោះលែង។ ករណីនេះពាក់ព័ន្ធប្រជាពលរដ្ឋប្រមាណ ១០០ គ្រួសារ និងដី ប្រមាណ ៥០០ ហិកតា។

**ការប្រើប្រាស់ដីសហគមន៍មិនត្រឹមត្រូវ**[4]**៖** អាជ្ញាធរមូលដ្ឋាន និងប្រធានការិយាល័យភូមិបាលស្រុក បានចាត់ចែងឲ្យមានការលក់ដីសហគមន៍ប្រហែល១០%(ប្រមាណ៦៤ហិកតា)ទៅឲ្យឈ្មួញ ទោះបីដីនោះបានកំណត់សម្រាប់ប្រយោជន៍រួមរបស់សហគមន៍ក៏ដោយ។

**ការដកហូតដីដោយអះអាងគម្រោងសាធារណៈ**[5]៖ អាជ្ញាធរ បានដកយកដីតាមមាត់ប្រឡាយ ដែលប្រជាពលរដ្ឋរស់នៅជាង ១០ ឆ្នាំ ដើម្បីអភិវឌ្ឍប្រព័ន្ធរំដោះទឹកជំនន់ ប៉ុន្តែមិនមានការដោះស្រាយសំណងដែលមានសមភាព និងតម្លាភាព។

**ការរំលោភលើដីជាអត្តសញ្ញាណវប្បធម៌ និងសិទ្ធិជនជាតិដើមភាគតិច**[6]**៖** មានការឈូសឆាយដីដំណាំ និងរំលោភយកដីព្រៃដែលជាទីកប់សពរបស់ជនជាតិដើមភាគតិច ហើយបន្ទាប់មកបានចេញប្លង់កម្មសិទ្ធិឲ្យទៅបុគ្គលមានអំណាច។

---

[2] Open Development Cambodia (2020): https://opendevelopmentcambodia.net/profiles/economic-land-concessions/ *គិតចាប់ពីចន្លោះឆ្នាំ១៩៩៦ ដល់ ២០១២ រដ្ឋាភិបាលកម្ពុជាបានផ្តល់ សម្បទានដីសេដ្ឋកិច្ចចំនួន២៩០គម្រោង ដែលមានផ្ទៃដីប្រមាណជាង ២.២៥លានហិចតា ហើយក្នុងនោះក្រុមហ៊ុនជាតិទទួលបាន៣៨%(១១២គម្រោង) និងក្រុមហ៊ុនបរទេសទទួលបាន៦២%រួមមានក្រុមហ៊ុនវៀតណាម ក្រុមហ៊ុនចិន ក្រុមហ៊ុនថៃ ក្រុមម៉ាឡេស៊ី ក្រុមហ៊ុនអាមេរិក និងក្រុមហ៊ុនស៊ីងហ្គាពួរជាដើម។*

[3] *របាយការណ៍អង្កេតសមាគមអាហុកលេខកូដករណី KTM 102111/01/2025 – កើតហេតុនៅភូមិត្បែង ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ*

[4] *របាយការណ៍អង្កេតសមាគមអាហុកលេខកូដករណី KCG 996/07/2025 – កើតហេតុនៅភូមិក្រសាំងដុះឡើង ឃុំក្បាលទឹក ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង*

[5] *របាយការណ៍អង្កេតសមាគមអាហុកលេខកូដករណី KDL 814/02/2025 – កើតហេតុនៅភូមិក្តីចាស់ ឃុំព្រែកល្វង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល*

[6] *របាយការណ៍អង្កេតសមាគមអាហុកលេខកូដករណី MDK 996/10/2025 – កើតហេតុនៅភូមិប៊ូស្រា ឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី*

**ការប្រើអំណាចបង្ខំដកយកដី**[7]៖ អភិបាលស្រុករួមជាមួយកំលាំងចម្រុះជិត៥០នាក់ បានបញ្ជាឲ្យឈូសឆាយដំណាំ និងរបងលួសបន្លារបស់តំណាងសហគមន៍ ហើយគម្រាមយកដីចំការបន្ថែមទៀត។

**ការគំរាមកំហែងដោយមន្ត្រីយោធា**[8]៖ មានឧត្តមសេនីម្នាក់ បានហាមឃាត់ និងគំរាមកំហែងមិនឲ្យសហគមន៍ដាំដុះ ឬប្រមូលផលលើដីដែលពួកគេកាន់កាប់ជិត ១០ឆ្នាំ។ ករណីនេះ អាជ្ញាធរមូលដ្ឋានមិនអាចដោះស្រាយបាន។ ដោយសារគ្មានដំណោះស្រាយសមរម្យ ករណីនេះបង្កើតចេញជារឿងព្រហ្មទណ្ឌចំនួន៤ករណីផ្សេងគ្នាគឺ មួយករណីប្ដឹងដោយភាគីសហគមន៍ និង៣ករណីប្ដឹងដោយភាគីអ្នកមានអំណាចដែលកំពុងបន្តនីតិវិធីនៅតុលាការដល់បច្ចុប្បន្ន។

**ការប្រើអាវុធគំរាមប្រជាពលរដ្ឋ**[9]៖ មេទាហានម្នាក់ បានប្រើអាវុធបាញ់គំរាមប្រជាពលរដ្ឋ មិនឲ្យអាស្រ័យផលស្រែចំការលើដីរបស់ខ្លួន ព្រមទាំងគម្រាម ឲ្យដកពាក្យបណ្ដឹងវិញ។

**ការឈូសឆាយដីព្រៃខណៈកំពុងដោះស្រាយ**[10]៖ បុគ្គលមានអំណាច បានប្រើគ្រឿងចក្រ ឈូសឆាយដីព្រៃសហគមន៍ ទោះបីករណីកំពុងស្ថិតក្នុងដំណើរការស្វែងរកដំណោះស្រាយក៏ដោយ។

**ការបំផ្លាញទ្រព្យសម្បត្តិប្រជាពលរដ្ឋ**[11]**៖** មានការប្រើគ្រឿងចក្រ បំផ្លាញរបង និងដំណាំរបស់ប្រជាពលរដ្ឋ ដោយអះអាងថាមានឯកសារកាន់កាប់ដី។

**ការប្រើប្រព័ន្ធតុលាការដើម្បីដាក់សម្ពាធ**[12]៖ មន្ត្រីអាជ្ញាធរមួយចំនួន បានយកដីរបស់ជនរងគ្រោះធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ហើយប្រើវិធានការណ៍ប្ដឹងទៅតុលាការ ដើម្បីដាក់សម្ពាធផ្លូវចិត្តលើជនរងគ្រោះ។

**គម្រោងអភិវឌ្ឍន៍មិនគោរពសិទ្ធិសហគមន៍**[13]៖ អ្នកមានទ្រព្យ(ក្រុមហ៊ុន) បានសហការជាមួយអាជ្ញាធរ រៀបចំឯកសារស្នើសុំអភិវឌ្ឍន៍គម្រោងជីកប្រឡាយបង្ហូរទឹក ដើម្បីលក់ឲ្យប្រជាពលរដ្ឋ ប្រើប្រាស់ក្នុងការធ្វើស្រែប្រាំង។ ជាពិសេសគម្រោងនេះបានអនុវត្តលើផ្លូវរទេះបុរាណនិងបង្កផលប៉ះពាល់ដល់សុវត្ថិភាពរបស់ប្រជាពលរដ្ឋប្រមាណ៥០គ្រួសារដែលរស់នៅជាប់មាត់ប្រឡាយនោះ។ ម្យ៉ាងទៀត គម្រោងនេះ ខកខានមិនបានអនុវត្តតាមគោលការណ៍ "ការយល់ព្រមដោយសេរី ជាមុន និងមានព័ត៌មានពេញលេញ (FPIC)" ដែលជាគោលការណ៍សំខាន់ក្នុងការការពារសិទ្ធិសហគមន៍។

**ការរំលោភកម្មសិទ្ធិដីសហគមន៍**[14]**៖** បុគ្គលមានទ្រព្យ បានលបលួចធ្វើការចុះបញ្ជីកម្មសិទ្ធិដីធ្លី លើដីដែលជាកម្មសិទ្ធិរួមរបស់ប្រជាពលរដ្ឋក្នុងភូមិ។ ដោយសាងសង់លំនៅដ្ឋានលើដីទីសក្ការៈបូជា ដែលជាកន្លែងប្រើប្រាស់រួមរបស់សហគមន៍ ដោយអះអាងថា ជាដីដែលបានចុះបញ្ជីត្រឹមត្រូវ។

**ការប្រើកម្លាំង និងគំរាមកំហែងក្នុងករណីវិវាទដីធ្លី**[15]៖ ក្រុមហ៊ុន បានប្រើគ្រឿងចក្រ ឈូសឆាយដីស្រែរបស់ប្រជាពលរដ្ឋ រួមទាំងជនជាតិដើមភាគតិច ខណៈករណីវិវាទនោះមិនទាន់បានដោះស្រាយសមរម្យនៅឡើយ។ ព្រមទាំងមានការគំរាម

---

[7] *របាយការណ៍អង្កេតសមាគមអាហុកលេខកូដករណី PST 37/01/2024 – កើតហេតុនៅភូមិក្បាលទាហាន ឃុំឈើតុំ ស្រុកក្រគរ ខេត្តពោធិ៍សាត់*

[8] *របាយការណ៍អង្កេតសមាគមអាហុកលេខកូដករណី RTK 1243/07/2025 – កើតហេតុនៅភូមិកាណាត ឃុំតាឡាវ ស្រុកអណ្ដូងមាស ខេត្តរតនៈគីរី*

[9] *របាយការណ៍អង្កេតសមាគមអាហុកលេខកូដករណី RTK 1241/06/2025 – កើតហេតុនៅភូមិពីរ ឃុំត្រពាំងច្រេស ស្រុកកូនមុំ ខេត្តរតនៈគីរី*

[10] *របាយការណ៍អង្កេតសមាគមអាហុកលេខកូដករណី RTK 1244/07/2025 – កើតហេតុនៅកាណាត ឃុំតាឡាវ ស្រុកអណ្ដូងមាស ខេត្តរតនៈគីរី*

[11] *របាយការណ៍អង្កេតសមាគមអាហុកលេខកូដករណី STG 1330/07/2025 – កើតហេតុនៅភូមិវាលពោធិ ឃុំអន្លង់ភេ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង*

[12] *របាយការណ៍អង្កេតសមាគមអាហុកលេខកូដករណី KPS 1642/02/2025 – កើតហេតុនៅភូមិអូរអង្គំ ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ*

[13] *របាយការណ៍អង្កេតសមាគមអាហុកលេខកូដករណី KTM 102115/06/2025 – កើតហេតុនៅភូមិត្រាំខ្លា ឃុំត្បែង ស្រុកកំពុងស្វាយ ខេត្តកំពង់ធំ*

[14] *របាយការណ៍អង្កេតសមាគមអាហុកលេខកូដករណី KPS 1656/05/2025 – កើតហេតុនៅភូមិត្បែអូរគេគីរ ឃុំតាំងក្រូច ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ*

[15] *របាយការណ៍អង្កេតសមាគមអាហុកលេខកូដករណី PVH 1556/08/2025 – កើតហេតុនៅភូមិអូរពោរ ឃុំរមណីយ ស្រុករវៀង ខេត្តព្រះវិហារ*

កំហែងដូចជា: "គំរាមបាញ់ និង គំរាមប្តឹងទៅតុលាការឲ្យចាប់ខ្លួនដាក់ពន្ធនាគារ" ដែលបង្កការភ័យខ្លាច និងដាក់សម្ពាធយ៉ាងខ្លាំងលើសហគមន៍ទាំងផ្លូវកាយ និងផ្លូវចិត្ត។

**ការរំលោភលើជីវប្បធម៌ និងធនធានធម្មជាតិ[16]៖** ក្រុមហ៊ុនសហការជាមួយអ្នកមានអំណាចនៅមូលដ្ឋាន បានប្រើគ្រឿងចក្រ ឈូសឆាយដីព្រៃជំនឿ និងដីស្រែចំការរបស់ជនជាតិដើមភាគតិចកួយ ដោយអះអាងថា ដីនោះស្ថិតនៅក្នុងតំបន់អភិរក្ស។ ការអះអាងនេះ មិនមានសមភាពត្រឹមត្រូវប្រសិនបើមិនមានការពិគ្រោះយោបល់ និងការយល់ព្រមពីសហគមន៍ជាមុន តាមគោលការណ៍ "ការយល់ព្រមដោយសេរី ជាមុន និងមានព័ត៌មានពេញលេញ (FPIC)"។

## IV. ផលវិបាកប៉ះពាល់ដល់សង្គម និងប្រជាពលរដ្ឋ

បញ្ហាសិទ្ធិដីធ្លីនាំឱ្យមានជម្លោះជាច្រើន ជាពិសេសបានកើតចេញជាបទល្មើសព្រហ្មទណ្ឌដូចជា ការដកហូតដីធ្លី ការបង្ខំផ្លាស់ទីលំនៅ និងពាក្យបណ្តឹងទៅតុលាការ ដែលប្រឈមនឹងការចាប់ឃុំខ្លួន។ បញ្ហាទាំងនេះ ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវភាពរស់នៅសមរម្យ សន្តិសុខរបស់ប្រជាសហគមន៍។ លើសពីនេះ វាក៏អាចបង្កើតអតុល្យភាពសង្គម និងប៉ះពាល់ដល់សិទ្ធិមនុស្ស ដូចជា សិទ្ធិលំនៅឋាន សិទ្ធិរស់នៅដោយមានសេចក្តីថ្លៃថ្នូរ និងសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់។

ករណីទាំងនេះ បានបង្កើតផលវិបាកធ្ងន់ធ្ងរដល់ប្រជាសហគមន៍រងគ្រោះផ្ទាល់ ហើយស្ថានភាពវិវាទដីធ្លីដែលកើតឡើងរវាងអាជ្ញាធរអ្នកមានអំណាច និងអ្នកមានទ្រព្យ(ក្រុមហ៊ុន) ជាមួយប្រជាពលរដ្ឋសហគមន៍ បានកើតចេញជាបទល្មើសព្រហ្មទណ្ឌជាច្រើនករណី ដែលបានប្តឹងដោយភាគីអ្នកមានអំណាច-មានទ្រព្យ ជាពិសេសបាន បង្កើតសម្ពាធផ្លូវចិត្ត-សុខុមាលភាពផ្លូវចិត្តយ៉ាងខ្លាំង ដាក់ស្តែងប្រជាសហគមន៍រងគ្រោះបានកំពុងប្រឈមមុខនឹង៖

**ផលវិបាកផ្លូវចិត្ត និងសិទ្ធិមូលដ្ឋាន៖** ប្រជាសហគមន៍រងគ្រោះប្រឈមមុខនឹង ភាពភ័យខ្លាចនិងសម្ពាធពីការកោះហៅចូលតុលាការប្រឈមមុខនឹងបណ្តឹងព្រហ្មទណ្ឌ និងការគំរាមកំហែងចាប់ឃុំខ្លួន និងប្រឈមមុខនឹងសុខុមាលភាពផ្លូវចិត្តធ្លាក់ចុះ រស់នៅក្នុងភាពអស្ថិរភាព និងអសន្តិសុខ។ កត្តានេះបង្ហាញថា សិទ្ធិមនុស្សជាមូលដ្ឋានត្រូវបានរួមតូច តាមរយៈការគំរាមកំហែងរបស់បុគ្គលមានទ្រព្យ និងការប្រើប្រព័ន្ធតុលាការ ដើម្បីទប់ស្កាត់ការតវ៉ារបស់ប្រជាសហគមន៍ បើយោងច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា៣៥ ធានាពលរដ្ឋមានសិទ្ធិតវ៉ា និងចូលរួមយ៉ាងសកម្មនៅក្នុងសង្គម និងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ មាត្រា៩ ការពារពីការចាប់-ឃុំខ្លួនតាមទំនើងចិត្ត មាត្រា១៩ធានាសេរីភាពបញ្ចេញមតិ និងមាត្រា២១ ធានាសេរីភាពប្រមូលផ្តុំដោយសន្តិវិធី។

**ផលវិបាកសេដ្ឋកិច្ច និងជីវភាពរស់នៅសមស្រប៖** ជនរងគ្រោះសហគមន៍ដីធ្លី បានបាត់បង់ដីធ្លីធ្វើកសិកម្មដែលជាប្រភពចំណូលសំខាន់សំរាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ នាំឲ្យកាន់តែក្រីក្រ និងមានបំណុលច្រើន។ ការដកហូតដីធ្លី ដោយមិនមានសំណងសមរម្យ គឺជាការរំលោភលើសិទ្ធិកម្មសិទ្ធិ ផ្ទុយស្មារតីរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា៤៤ ធានាសិទ្ធិកម្មសិទ្ធិដីធ្លី និងច្បាប់ភូមិបាលឆ្នាំ២០០១បានធានាសិទ្ធិភោគៈដោយសន្តិវិធី ព្រមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ មាត្រា១១ ធានាសិទ្ធិលំនៅដ្ឋាន និងជីវភាពរស់នៅសមរម្យ។

**ផលវិបាកសង្គម និងស្ថេរភាពសហគមន៍៖** ជនរងគ្រោះដីធ្លី មានស្ថានភាពលំបាក ដោយបែកបាក់គ្រួសារ បង្ខំចិត្តធ្វើ ចំណាកស្រុក មានការភិតភ័យរត់គេចពីការចាប់ឃុំខ្លួន។ កត្តានេះ អាចប្រឈមនឹងការបាត់បង់សុវត្ថិភាពសង្គម ជា

[16] *របាយការណ៍អង្កេតសមាគមអាហុកលេខកូដករណី PVH 1545/01/2025 – កើតហេតុនៅភូមិណារ៉ុង ឃុំឆែបពីរ ស្រុកឆែប ខេត្តព្រះវិហារ*

ពិសេសផ្ទុយស្មារតីរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា មាត្រា៣៦ធានាសិទ្ធិរស់នៅមានសុវត្ថិភាពនិងមុខរបរសមរម្យ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ មាត្រា១០ បានធានាការពារគ្រួសារ។

**ផលលំបាកសិទ្ធិជនជាតិដើមភាគតិចៈ** វិវាទដីធ្លី នាំឲ្យជនរងគ្រោះជាជនជាតិដើមភាគតិច បាត់បង់ដីវប្បធម៌ ទីសក្ការៈ អត្តសញ្ញាណ និងប្រពៃណីទំនៀមទំម្លាប់ល្អ។ កត្តានេះអាចផ្ទុយស្មារតីគោលការណ៍"ការយល់ព្រមជាមុនដោយសេរី និងមានព័ត៌មានពេញលេញ (FPIC)" និងច្បាប់ភូមិបាល២០០១ មាត្រា២៣សិទ្ធិជនជាតិដើមភាគតិច និងសេចក្តីប្រកាសជាសកលអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច មាត្រា១០ ធានាការមិនបណ្តេញចេញជនជាតិដើមភាគតិចពីដីរបស់គាត់ដោយគ្មានការយល់ព្រមជាមុន និងមាត្រា២៦ សិទ្ធិជនជាតិដើមភាគតិចរស់នៅលើដី។

**ផលវិបាកផ្នែកច្បាប់ និងយុត្តិធម៌ៈ** ការប្រើបទល្មើសព្រហ្មទណ្ឌ ដើម្បីដាក់សម្ពាធ ជនរងគ្រោះវិវាទដីធ្លី ការរឹតត្បឹតការមិនទទួលពាក្យបណ្តឹងរបស់អាជ្ញាធរមូលដ្ឋាន ករណីវិវាទដីធ្លីជាមួយអ្នកមានទ្រព្យ-មានអំណាច និងការគម្រាមឲ្យជនរងគ្រោះវិវាទដីធ្លីដកពាក្យបណ្តឹង អាចប្រឈមមតិសាធារណៈជនថា"ខ្វះឯករាជភាពតុលាការ និងនិទណ្ឌភាព" ដែលនាំឲ្យមានការបាត់បង់ទំនុកចិត្តក្នុងការស្វែងរកយុត្តិធម៌ ជាមួយប្រព័ន្ធតុលាការ និងប៉ះពាល់ធ្ងន់ធ្ងរដល់គោលការណ៍នីតិរដ្ឋ។ សកម្មភាពទាំងនេះ ផ្ទុយស្មារតីក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា៤០សិទ្ធិប្តឹងទៅអាជ្ញាធរ និងក្រមព្រហ្មទណ្ឌមាត្រា៥១៩ ការបដិសេធអនុវត្តការកិច្ចដោយមន្ត្រីអាជ្ញាធរ មាត្រា២៣២ការគំរាមកំហែងគ្រប់ទម្រង់ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា១៤ សិទ្ធិស្មើគ្នាចំពោះការទទួលបានការជំនុំជម្រះយុត្តិធម៌។

## V. ការវាយតម្លៃប្រសិទ្ធិភាពនៃនិយ័តកម្មច្បាប់

ប្រទេសកម្ពុជាមានបញ្ញាតិច្បាប់ដីធ្លីដែលមានរចនាសម្ព័ន្ធល្អ ប៉ុន្តែប្រសិទ្ធិភាពអនុវត្តបញ្ញាតិច្បាប់នៅមានកម្រិត។ គម្លាតរវាងច្បាប់ និងការអនុវត្ត បណ្តាលមកពីអំពើពុករលួយ ការខ្វះគណនេយ្យភាព និងឥទ្ធិពលអំណាច។ ដូច្នេះ និយ័តកម្មច្បាប់ មិនអាចសម្រេចគោលបំណងបានពេញលេញ ប្រសិនបើគ្មានការអនុវត្តត្រឹមត្រូវ និងស្មើភាព។

| បញ្ញាតិច្បាប់មានភាពរឹងមាំ-មានរចនាសម្ព័ន្ធល្អ | ការអនុវត្តន៍ទន់ខ្សោយខ្វះប្រសិទ្ធិភាព |
|---|---|
| គម្លាតរវាងទ្រឹស្តី | ការអនុវត្តន៍ |
| គណនេយ្យភាព-ឥទ្ធិពលអំណាច-អំពើពុករលួយ | ប្រសិទ្ធិភាពនៃការអនុវត្តន៍ |

ជារួមករណីនេះ បានបង្ហាញអំពី បញ្ហាសំខាន់ ដែលជាឬសគល់ នាំឲ្យមានការរំលោភដីធ្លីដោយបុគ្គលមានអំណាច-មានទ្រព្យ គឺអាចមកពីការប្រើអំណាចលើសព្រំដែននៃច្បាប់ ការប្រើប្រាស់ធនធានសាធារណៈខុសគោលបំណង ការរំលោភសិទ្ធិដីធ្លីនិងសិទ្ធិមនុស្ស និងការប្រើកម្លាំងប្រដាប់អាវុធ និងប្រព័ន្ធតុលាការ ដើម្បីដាក់សម្ពាធប្រជាពលរដ្ឋ។ ម៉្យាងទៀតលំនាំករណីនេះ គឺបណ្តាលមកពីទំនាក់ទំនងសហការរវាងអាជ្ញាធរ-បុគ្គលមានអំណាចនិងអ្នកមានទ្រព្យ ប្រើយុទ្ធសាស្ត្រចម្រុះរួមមាន ការគំរាមកំហែងការចាប់ខ្លួន ការបង្ខំឲ្យចុះកិច្ចសន្យា និងប្រើយន្តការតុលាការ។

វិវាទដីធ្លីដែលពាក់ព័ន្ធនឹងបុគ្គលមានអំណាច-មានទ្រព្យ មិនត្រឹមតែជាបញ្ហាធនធានដីធ្លីប៉ុណ្ណោះទេ ប៉ុន្តែជាបញ្ហាដែលមានទំនាក់ទំនងជាមួយនឹងសិទ្ធិមនុស្ស សន្តិសុខសង្គម និងអភិបាលកិច្ចល្អ។ ប្រសិនបើមិនមានដំណោះស្រាយត្រឹមត្រូវទេ អាចនាំឲ្យបន្តប៉ះពាល់ដល់ស្ថិរភាពសង្គម ការកើនឡើងនៃភាពក្រីក្រក្នុងសង្គម បាត់បង់ទំនុកចិត្តលើអាជ្ញាធរ និងប្រព័ន្ធយុត្តិធម៌ និងមូលដ្ឋានការអភិវឌ្ឍន៍រយៈពេលវែង។

## VI. សេចក្តីសន្និដ្ឋាន

ស្ថានភាពសិទ្ធិដីធ្លីនៅកម្ពុជា បង្ហាញពីភាពខុសគ្នារវាងនិយ័តកម្មច្បាប់ និងការអនុវត្តជាក់ស្តែង។ ទោះបីជាមានច្បាប់ល្អក៏ដោយ ក៏កត្តាមួយចំនួនដូចជា អំពើពុករលួយ ខ្វះតម្លាភាព និងឥទ្ធិពលអំណាច អាចបង្កឱ្យមានភាពមិនស្មើភាពក្នុងសង្គម។ ដើម្បីធានាសិទ្ធិដីធ្លីស្មើភាព កម្ពុជាត្រូវការកែលម្អទាំងផ្នែកច្បាប់ និងការអនុវត្ត ដើម្បីឱ្យប្រជាពលរដ្ឋទាំងអស់ទទួលបានអត្ថប្រយោជន៍ស្មើគ្នា។

យោងតាមទិន្នន័យឆ្នាំ២០២៥ បញ្ហាវិវាទដីធ្លីនៅកម្ពុជា បន្តមានលក្ខណៈធ្ងន់ធ្ងរ-រ៉ាំរ៉ៃ និងស្មុគស្មាញ ដោយមានករណីថ្មីចំនួន៤៥ករណីបន្ថែមលើករណីចាស់ៗជាច្រើនដែលមិនទាន់មានដំណោះស្រាយសមរម្យ។ ករណីទាំងនេះប៉ះពាល់ដល់ប្រជាពលរដ្ឋចំនួន៥,៥២០ គ្រួសារ (១៤,៧៩៨ នាក់) រួមទាំងជនជាតិដើមភាគតិច៧,៣៥១នាក់ និងផ្ទៃដីប្រមាណ ១១៥,៤១៣ ហិកតា។ ក្នុងនោះ ភាគរយខ្ពស់នៃវិវាទពាក់ព័ន្ធនឹងការរំលោភដីធ្លីដោយបុគ្គលមានអំណាច (៤២%) និងអ្នកមានទ្រព្យ/ក្រុមហ៊ុន (២០%) ដែលបង្ហាញពីឥទ្ធិពលខ្លាំងរបស់ក្រុមអាជ្ញាធរមានអំណាចលើការប្រើប្រាស់ធនធានដីធ្លី-ធនធានធម្មជាតិ។

លក្ខណៈសំខាន់មួយនៃវិវាទទាំងនេះ គឺការប្រើអំណាចលើសគោលបំណងច្បាប់បានកំណត់ ដូចជា ការដកហូតដីដោយមិនមានសំណងសមរម្យ ការប្រើកម្លាំង ឬអាវុធគំរាមកំហែង ការបំផ្លាញទ្រព្យសម្បត្តិ-ផលដំណាំកសិកម្ម និងការប្រើប្រព័ន្ធតុលាការជាឧបករណ៍ដាក់សម្ពាធលើប្រជាសហគមន៍។ ការអនុវត្តច្បាប់ដីធ្លីបង្ហាញពីការខ្វះតម្លាភាព និងឯករាជ្យភាព ដែលបណ្តាលឲ្យមានគម្លាតយ៉ាងធំ រវាងទ្រឹស្តីបញ្ញត្តិច្បាប់ និងការអនុវត្តជាក់ស្តែង។

ម្យ៉ាងទៀត បញ្ហានេះប៉ះពាល់យ៉ាងធ្ងន់ដល់សិទ្ធិមនុស្ស ដោយរួមមានសិទ្ធិកម្មសិទ្ធិ សិទ្ធិលំនៅឋាន សិទ្ធិរស់នៅមានសេចក្តីថ្លៃថ្នូរ និងសិទ្ធិតវ៉ាដោយសន្តិវិធី។ ជាពិសេស ជនជាតិដើមភាគតិចប្រឈមនឹងការបាត់បង់ជីវប្បធម៌ អត្តសញ្ញាណ និងធនធានធម្មជាតិ ដោយមិនគោរពគោលការណ៍ "ការយល់ព្រមជាមុនដោយសេរី និងមានព័ត៌មានពេញលេញ (FPIC)"។ ផលវិបាកនៃវិវាទដីធ្លី មិនត្រឹមតែប៉ះពាល់ផ្នែកច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែប៉ះពាល់ដល់សង្គម និងជីវភាពប្រជាពលរដ្ឋ ដូចជា៖ **(បញ្ហាផ្លូវចិត្ត)** ភាពភ័យខ្លាច សម្ពាធ និងអស្ថិរភាព - **(បញ្ហាសេដ្ឋកិច្ច)** បាត់បង់ដីធ្លី និងប្រភពចំណូល បង្កើនភាពក្រីក្រ និងបំណុល - **(បញ្ហាសង្គម)** បែកបាក់គ្រួសារ ចំណាកស្រុក និងអសន្តិសុខសង្គម - **(បញ្ហាច្បាប់)** ការបាត់បង់ទំនុកចិត្តលើប្រព័ន្ធយុត្តិធម៌ និងនិទណ្ឌភាព។

សរុបមកវិវាទដីធ្លីនៅកម្ពុជា គឺមិនមែនជាបញ្ហាបច្ចេកទេសធម្មតាទេ ប៉ុន្តែជាបញ្ហាដែលជាប់ពាក់ព័ន្ធយ៉ាងជ្រាលជ្រៅនឹង **អំណាច សេដ្ឋកិច្ច សិទ្ធិមនុស្ស និងអភិបាលកិច្ច**។ បញ្ហាគន្លឹះសំខានៗរួមមាន ការប្រើអំណាចលើសគោលបំណងច្បាប់កំណត់ អំពើពុករលួយ ខ្វះគណនេយ្យភាព និងការសហការរវាងអាជ្ញាធរមានអំណាច និងអ្នកមានទ្រព្យ(ក្រុមហ៊ុន)។

## VII. ដំណោះស្រាយ និងអនុសាសន៍

ដើម្បីកែលំអរស្ថានភាពការអនុវត្តន៍ច្បាប់ ក្នុងការគ្រប់គ្រងដីធ្លីគឺត្រូវតែ៖ ពង្រឹងប្រសិទ្ធិភាពការអនុវត្តន៍ច្បាប់ឲ្យមានតម្លាភាព និងធានាយុត្តិធម៌ស្មើភាព ធានាឯករាជ្យភាពតុលាការ គោរពសិទ្ធិសហគមន៍ និងជនជាតិដើមភាគតិច ជាពិសេសគោលការណ៍ "ការព្រមព្រៀងជាមុន ដោយសេរី និងមានព័ត៌មានគ្រប់គ្រាន់ (FPIC)" និងទប់ស្កាត់អំពើពុករលួយ និងការប្រើអំណាចខុសគោលបំណងច្បាប់។ ដូច្នោះ បើគ្មានវិធានការណ៍ជាក់ស្តែង វិវាទដីធ្លីនឹងបន្តបង្កផលប៉ះពាល់ធ្ងន់ធ្ងរ

ដល់ស្ថិរភាពសេដ្ឋកិច្ច-សង្គម  ការកើនឡើងនៃភាពក្រីក្រ ការបាត់បង់ទំនុកចិត្តលើរដ្ឋាភិបាល និងប្រព័ន្ធយុត្តិធម៌ ដែលអាចរារាំងការអភិវឌ្ឍន៍រយៈពេលវែង។

**អនុសាសន៍**

1. បញ្ឈប់ការប្រើអំណាច ឬ កម្លាំងប្រដាប់អាវុធ គំរាមកំហែងបង្ក្រាបការតវ៉ាទាមទារដោយសន្តិវិធី
2. បញ្ឈប់ការប្រើបទល្មើសព្រហ្មទណ្ឌក្នុងការចោទប្រកាន់ឬចាប់ឃុំខ្លួន ដើម្បីជាការដាក់សម្ពាធលើភាគី ជាពិសេសប្រជាពលរដ្ឋសហគមន៍ ក្នុងរឿងវិវាទដីធ្លី"ត្រូវដោះស្រាយវិវាទដីធ្លីជាមុន ដោយបង្អង់រឿងព្រហ្មទណ្ឌ" ។
3. ធានាការអនុវត្តឲ្យបានត្រឹមត្រូវតាមគោលការណ៍ច្បាប់ គឺផ្តល់សំណងជាមុនដោយត្រឹមត្រូវ សមរម្យនិងយុត្តិធម៌ក្នុងករណីចាំបាច់ ចំពោះការដកហូតកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ ។
4. ធានាអនុវត្តប្រកបដោយប្រសិទ្ធិភាពនូវគោលការណ៍ ឯករាជ្យ តម្លាភាព និងឆាប់រហ័ស ក្នុងការដោះស្រាយវិវាទដីធ្លី ព្រមទាំងដាក់ទោសទណ្ឌចំពោះមន្ត្រីណាដែលប្រើតួនាទីមិនត្រឹមត្រូវ ។
5. ការពារសិទ្ធិសហគមន៍ និងជនជាតិដើមភាគតិច  ដោយធានាអនុវត្តគោលការណ៍"ការយល់ព្រមជាមុនដោយសេរីនិង មានព័ត៌មានពេញលេញ (FPIC)"។

- ចប់ -